**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ៦៧៦ ទស.ររទម

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៤

**ជម្រាបជូន**

**លោកប្រធាន មជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ**: សំណើសុំចាត់មន្ត្រីជំនាញ០២រូបជាសមាជិក និងលេខាធិការដ្ឋានដើម្បីដាក់បញ្ចូលក្នុងគណៈកម្មការអន្តរក្រសួងស្តីពីការរៀបចំអភិវឌ្ឍ និងគ្រប់គ្រងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ។

**យោង** :-អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ។

-សេចក្តីសម្រេចលេខ ៤៨ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ដោយសមាជិក និងលេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួងអាណត្តិទី៤មួយចំនួន មានការផ្លាស់ប្តូរតួនាទីភារកិច្ចទៅបម្រើការងារនៅស្ថាប័នថ្មី ដូច្នេះដើម្បីបន្តគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ឲ្យសម្រេចបានជោគជ័យ និងប្រកបដោយនិរន្តរភាព ក្រសួងទេសចរណ៍នឹងរៀបចំកែសម្រួលសមាសភាពថ្មី ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេចចាត់មន្ត្រីជំនាញ០២រូប ចូលសមាជិក និងលេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួងដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងទេសចរណ៍

**ថោង ខុន**

សូមមេត្តាទំនាក់ទំនង
- លោក កែន សុភី: ០៩២ ៦៥៦ ៧៩៧
- លោក ស្រេន សុវណ្ណារ៉ា:០១៧ ២២៦ ១៧៧